FAQ សម្រាប់ម្ចាស់សត្វចិញ្ចឹម

# ជំងឺរលាកផ្លូវដង្ហើមកូរ៉ូណា (COVID-19)

**បច្ចុប្បន្នភាពថ្មីៗ៖**
11/6/20៖ បានបន្ថែមបច្ចុប្បន្នភាពទាក់ទងនឹងការចម្លងជំងឺ។



## 1. តើមេរោគកូរ៉ូណាគឺជាអ្វី?

មានមេរោគកូរ៉ូណាជាច្រើនប្រភេទ ដែលបង្កឲ្យមានជំងឺនៅលើមនុស្ស និងសត្វ។ មេរោគទាំងនេះ គឺខុសៗគ្នា និងមិនសូវមានទំនាក់ទំនងនឹងគ្នាប៉ុន្មានទេ។ នៅលើមនុស្ស មេរោគកូរ៉ូណាមួយចំនួនបង្កឲ្យមានជំងឺផ្លូវដង្ហើមខាងលើកម្រិតស្រាល ដូចជាផ្ដាសាយទូទៅ ខណៈដែលមួយចំនួនតូចអាចបង្កឲ្យមានជំងឺធ្ងន់ធ្ងរដូចជា SARS និង MERS។ នៅលើសត្វមានមេរោគកូរ៉ូណាដែលអាចបង្កឲ្យមានរោគសញ្ញាជាច្រើននៅលើសត្វចិញ្ចឹម ដូចជាជំងឺផ្លូវដង្ហើម ឬរាគរូស អាស្រ័យលើប្រភេទសត្វ និងប្រភេទមេរោគកូរ៉ូណាជាក់លាក់។ មកទល់ពេលនេះ មេរោគកូរ៉ូណាដែលបង្កជំងឺនៅលើសត្វចិញ្ចឹម មិនត្រូវបានគេដឹងថាឆ្លងទៅមនុស្សទេ។

## 2. តើជំងឺ COVID-19 គឺជាអ្វី?

មេរោគកូរ៉ូណាមួយចំនួនមកពីសត្វអាចវិវឌ្ឍ (ផ្លាស់ប្ដូរ) ទៅជាមេរោគកូរ៉ូណាថ្មីកើតលើមនុស្ស ដែលអាចរីករាលដាលពីមនុស្សទៅមនុស្សបាន។ នេះគឺជាអ្វីដែលបានកើតឡើងជាមួយមេរោគកូរ៉ូណាដែលគេស្គាល់ថា SARS-CoV-2 ដែលបង្កឲ្យមានជំងឺមួយហៅថា COVID-19 នៅលើមនុស្ស។

## 3. តើជំងឺ COVID-19 ឆ្លងដោយរបៀបណារវាងមនុស្ស?

ដូចជំងឺផ្លូវដង្ហើមផ្សេងៗទៀតដែរ មេរោគកូរ៉ូណាដែលកើតលើមនុស្សជាទូទៅឆ្លងទៅមនុស្សផ្សេងទៀតពីអ្នកមានផ្ទុកជំងឺតាមរយៈ៖

- តំណក់ទឹកតូចៗដែលកើតឡើងតាមរយៈការក្អក កណ្ដាស់ឬការនិយាយ
- ការប៉ះពាល់ជិតស្និទ្ធ ដូចជាការថែទាំអ្នកដែលកើតជំងឺ
- ជំងឺ COVID-19 ក៏អាចឆ្លងតាមរយៈការប៉ះផ្ទៃឬវត្ថុដែលមានមេរោគនៅលើនោះ ហើយបន្ទាប់មកប៉ះមាត់ ច្រមុះ ឬភ្នែកផងដែរ ប៉ុន្តែវាមិនត្រូវបានគេគិតថាជាវិធីចម្បងដែលមេរោគឆ្លងនោះទេ។ មនុស្សមួយចំនួនឆ្លងជំងឺ COVID-19 ដោយមិនចេញរោគសញ្ញាឡើយ ប៉ុន្តែពួកគេនៅតែអាចចម្លងមេរោគនេះទៅអកដទៃបាន។

## 4. តើសត្វចិញ្ចឹមអាចឈឺដោយសារ និងចម្លងជំងឺ COVID-19 ដែរឬទេ?

មកទល់បច្ចុប្បន្ននេះ នៅសហរដ្ឋអាមេរិកមានរបាយការណ៍ជាច្រើនបង្ហាញថាសត្វឆ្មើតេស្តវិជ្ជមានសម្រាប់ជំងឺ COVID-19 ភាគច្រើនបន្ទាប់ពីការប៉ះពាល់ជិតស្និទ្ធជាមួយមនុស្សដែលមានជំងឺ COVID-19។ វាបង្ហាញថាក្នុងស្ថានភាពខ្លះ មេរោគនេះអាចឆ្លងពីមនុស្សទៅសត្វបាន។ ទោះជាយ៉ាងណាក៏ដោយ មិនទាន់មានរបាយការណ៍បង្ហាញថាមនុស្ស ឬម្ចាស់សត្វចិញ្ចឹមឆ្លងជំងឺ COVID-19 ពីសត្វចិញ្ចឹមរបស់ខ្លួនឡើយ។ នៅពេលនេះ មិនមានភស្តុតាងបង្ហាញថាសត្វចិញ្ចឹម រួមទាំងសត្វឆ្កែ និងសត្វឆ្មាអាចចម្លងជំងឺ COVID-19 ទៅមនុស្សបាននោះទេ។

### សារសំខាន់ៗ៖

មិនមានភស្តុតាងណាមួយបង្ហាញថាសត្វចិញ្ចឹមអាចចម្លងជំងឺ COVID-19 ទៅមនុស្សបាននោះទេ។

ទោះជាយ៉ាងណាក៏ដោយ សត្វចិញ្ចឹមអាចចម្លងជំងឺផ្សេងៗទៀតទៅមនុស្សបាន ដូច្នេះចូរលាងសម្អាតដៃរបស់អ្នកបន្ទាប់ពីចាត់ចែងសត្វចិញ្ចឹម។

អនាម័យល្អ និងការថែទាំបសុព្យាបាលជួយរក្សាឲ្យសត្វចិញ្ចឹម និងមនុស្សមានសុខភាពល្អជានិច្ច។

តើសាធារណជនអាចរកព័ត៌មានបន្ថែមនៅកន្លែងណាបាន?

**Los Angeles County Department of Public Health**
ទូរសព្ទទៅលេខ 2-1-1
**California Department of Public Health**
916-558-1784
**Centers for Disease Control and Prevention**
800-CDC-INFO
800-232-4636

# ជំងឺរលាកផ្លូវដង្ហើមកូរ៉ូណា (COVID-19)

## 5. ខ្ញុំមានសត្វចិញ្ចឹមមួយក្បាល។ តើខ្ញុំគួរធ្វើអ្វីខ្លះ?

ទោះបីជាហានិភ័យ (risk) នៃការឆ្លងជំងឺ COVID-19 នៅលើសត្វចិញ្ចឹមមានកម្រិតទាបក៏ដោយ មានជំងឺផ្សេងៗទៀតជាច្រើនដែលអាចធ្វើឲ្យសត្វឈឺ និងអាចចម្លងពីសត្វទៅមនុស្ស។ អាស្រ័យហេតុនេះ ជាការល្អគួរលាងសម្អាតដៃបន្ទាប់ពីនៅជិតសត្វជានិច្ច។ រាប់បញ្ចូលសត្វចិញ្ចឹមនៅក្នុងការធ្វើផែនការត្រៀមខ្លួនរបស់គ្រួសារអ្នក។

## 6. ខ្ញុំកើតជំងឺ COVID-19 ហើយខ្ញុំមានសត្វចិញ្ចឹម ឬសត្វផ្សេងៗទៀត។ តើខ្ញុំគួរធ្វើអ្វីខ្លះ?

នៅពេលដែលអ្នកកើតជំងឺ COVID-19 អ្នកគួរតែរឹតបន្តឹងការប៉ះពាល់ជាមួយសត្វចិញ្ចឹម ឬសត្វផ្សេងៗទៀត ដូចដែលអ្នកធ្វើជាមួយមនុស្សផ្សេងទៀតដែរ។ នៅពេលអាចធ្វើបាន ចូរឲ្យសមាជិកម្នាក់ទៀតក្នុងគ្រួសាររបស់អ្នកថែទាំសត្វរបស់អ្នកខណៈដែលអ្នកឈឺ។ បើសិនជាអ្នកឈឺ ចូរចៀសវាងការប៉ះពាល់ជាមួយសត្វចិញ្ចឹម រួមទាំងការអង្អែល ឱបរឹត ការត្រូវបានថើមឬលិត និងការចែករំលែកចំណីអាហារ។ បើសិនជាអ្នកចាំបាច់ត្រូវតែថែទាំសត្វចិញ្ចឹមរបស់អ្នក ឬត្រូវនៅជិតសត្វខណៈដែលអ្នកឈឺ ចូរលាងដៃរបស់អ្នកមុននិងក្រោយពីអ្នកប៉ះពាល់សត្វចិញ្ចឹម និងត្រូវពាក់ម៉ាស់ ឬវត្ថុបាំងមុខ។ម្យ៉ាងវិញទៀត សូមជូនដំណឹងដល់មន្ត្រីសុខភាពសាធារណៈរបស់អ្នកថា អ្នកមានសត្វនៅផ្ទះរបស់អ្នក។

## 7. តើខ្ញុំអាចបណ្តើរសត្វឆ្កែរបស់ខ្ញុំបានដែរឬទេ បើសិនជាខ្ញុំស្ថិតក្នុងការឲ្យនៅដាច់ដោយឡែក ឬចត្តាឡីស័ក្ត?

ទេ។ បើសិនជាអ្នកមានអារម្មណ៍ថាឈឺ និងត្រូវបានដាក់ក្រោមការឲ្យនៅដាច់ដោយឡែកសម្រាប់ជំងឺ COVID-19 ឬអ្នកត្រូវបានដាក់ក្រោមការនៅដាច់ដោយឡែក (ចត្តាឡីស័ក្ត) រយៈពេល 14 ថ្ងៃ បន្ទាប់ពីការប៉ះពាល់ជាមួយជំងឺ COVID-19 អ្នកមិនអាចចេញពីផ្ទះរបស់អ្នកក្នុងអំឡុងពេលនោះបានឡើយ។ ចូរឲ្យសមាជិកគ្រួសារម្នាក់បណ្តើរសត្វឆ្កែរបស់អ្នកក្នុងអំឡុងពេលនោះ។ ឬម្យ៉ាងទៀត ចូរស្នើ ឬជួលនរណាម្នាក់ផ្សេងឲ្យបណ្តើរសត្វឆ្កែរបស់អ្នក។ នៅពេលដែលជននោះមកដល់ដើម្បីយកសត្វឆ្កែរបស់អ្នកទៅដើរលេង អ្នកទាំងពីរគួរតែពាក់វត្ថុបាំងមុខនិងព្យាយាមស្ថិតនៅគំលាតពីគ្នា 6 ហ្វីតឬឆ្ងាយជាងនេះ។ លាងដៃរបស់អ្នកមុននិងក្រោយពីដំណើរការផ្ទេរសត្វឆ្កែរវាងមនុស្ស។ ចូរពិចារណាឲ្យអ្នកបណ្តើរសត្វឆ្កែប្រើខ្សែផ្ទាល់ខ្លួនរបស់គេ។

## 8. ខ្ញុំចាំបាច់ត្រូវយកសត្វចិញ្ចឹមរបស់ខ្ញុំទៅជួបពេទ្យសត្វ។ តើខ្ញុំរក្សាគំលាតសង្គមដោយរបៀបណា?

ពេទ្យសត្វរបស់អ្នកប្រហែលជាបានកែតម្រូវប្រតិបត្តិការរបស់ខ្លួនដើម្បីធានាបាននូវការរក្សាគំលាតសង្គម។ ក្នុងករណីខ្លះ ពួកគេអាចនឹងចាំបាច់ត្រូវលុបចោល ឬកែប្រែដំណើរការនិងការណាត់ជួប។ ឧទាហរណ៍ ពួកគេអាចឲ្យអ្នករង់ចាំនៅខាងក្រៅគ្លីនិក មើលសត្វរបស់អ្នកនៅក្នុងរថយន្ត ឬអាចមានការណាត់ជួបថែទាំតាមទូរសព្ទ (telemedicine)។ អ្នកត្រូវតែពាក់វត្ថុបាំងមុខ នៅពេលប្រាស្រ័យទាក់ទងជាមួយបុគ្គលិកពេទ្យសត្វ។ វិជ្ជាជីវៈវេជ្ជសាស្ត្រទាំងអស់កំពុងជួបបញ្ហាប្រឈមមុខជាច្រើន។ ចូរទូរសព្ទទៅពេទ្យសត្វរបស់អ្នកជាមុន និងធ្វើការជាមួយពួកគេឲ្យបានជិតស្និទ្ធដើម្បីកំណត់ពីវិធីល្អបំផុតដើម្បីការពារសុខភាពរបស់ពួកគេ សុខភាពរបស់អ្នក និងសុខភាពសត្វរបស់អ្នក។ បើសិនជាអ្នកឈឺ ហើយសត្វចិញ្ចឹម របស់អ្នកត្រូវការជួបជាមួយពេទ្យសត្វ ចូរព្យាយាមរៀបចំឲ្យនរណាម្នាក់ផ្សេងយកសត្វចិញ្ចឹមរបស់អ្នកទៅ និងជូនដំណឹង ដល់ទីកន្លែងនោះមុនពេលសត្វចិញ្ចឹមរបស់អ្នកទៅដល់ ដើម្បីឲ្យពួកគេអាចត្រៀមខ្លួនបានសមស្រប។

មានជំហានសាមញ្ញៗមួយចំនួន ដែលអ្នកអាចធ្វើបានដើម្បីការពារសុខភាពសត្វចិញ្ចឹម និងក្រុមគ្រួសាររបស់អ្នកពីជំងឺភាគច្រើន៖

- បង្កើតទំនាក់ទំនងជាមួយពេទ្យសត្វសម្រាប់សត្វចិញ្ចឹមរបស់អ្នក។
- រក្សាការចាក់វ៉ាក់សាំងសត្វចិញ្ចឹមរបស់អ្នកឲ្យនៅបច្ចុប្បន្ន និងធ្វើការគ្រប់គ្រងចៃសត្វចិញ្ចឹម។
- លាងសម្អាតដៃរបស់អ្នកបន្ទាប់ពីចាត់ចែងសត្វចិញ្ចឹមរបស់អ្នក កន្លែងដេកនិងរបស់លេង ឬចានគោមរបស់វា។
- បើសិនជាអ្នកឈឺ ចូររក្សាគំលាតពីអ្នកដទៃនិងសត្វចិញ្ចឹម និងលាងសម្អាតដៃរបស់អ្នកឲ្យបានញឹកញាប់។
- បើសិនជាសត្វចិញ្ចឹមរបស់អ្នកឈឺ ចូរទាក់ទងពេទ្យសត្វ។ រក្សាវាឲ្យឆ្ងាយពីសត្វចិញ្ចឹមផ្សេងទៀត រហូតដល់វាជាសះស្បើយ។ លាងសម្អាតដៃរបស់អ្នករៀងរាល់ពេល បន្ទាប់ពីអ្នកថែទាំវា។